# សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភា

## កម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី

២០
២៦





ខែមីនា ឆ្នាំ២០២៦

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំសូមជម្រាបជូនថា គំនិតដើមនៃការសិក្សានេះ កើតឡើងដោយសារទស្សនទានរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការពង្រឹងការទូតសភា និងគណនេយ្យភាពសភាជាមួយអង្គបោះឆ្នោត និងប្រជាជននៅតាមមូលដ្ឋានសម្រាប់ព្រឹទ្ធសភា នីតិកាលទី៥។

ដើម្បីពង្រឹងគណនេយ្យភាពសភា ពោលគឺបង្កើនការទទួលខុសត្រូវ និងបង្ខិតសមាជិកព្រឹទ្ធសភា ឱ្យកាន់តែជិតជាមួយអង្គបោះឆ្នោត និងប្រជាជននៅតាមមូលដ្ឋាន គណៈកម្មការពិសេស ត្រូវបានបង្កើតឡើងដើម្បីសិក្សាស្រាវជ្រាវអំពី ប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជាប្រៀបធៀបជាមួយ ប្រព័ន្ធបោះឆ្នោតសភាជាន់ខ្ពស់ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ ឥណ្ឌូណេស៊ី បារាំង អង់គ្លេស អាម៉េរិក កាណាដា និងអូស្ត្រាលី។

គណៈកម្មការពិសេស បានបំពេញភារកិច្ចរបស់ខ្លួន ដោយបានសិក្សាស្រាវជ្រាវ ពិភាក្សា រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងរៀបចំជាអត្ថបទស្រាវជ្រាវ រហូតទទួលបានលទ្ធផលជាទីគាប់ចិត្ត ពោលគឺការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវចំនួនពីរដូចខាងក្រោម៖

១. សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី និង

២. សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភាកម្ពុជា បារាំង អង់គ្លេស អាម៉េរិក កាណាដា និងអូស្ត្រាលី។

តាងនាមគណៈកម្មការពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណចំពោះ **សម្ដេចអគ្គមហាសេនាបតីតេជោ** ដែលតែងតែផ្ដល់យោបល់ណែនាំ និងលើកទឹកចិត្តដល់ការស្រាវជ្រាវរបស់គណៈកម្មការពិសេស។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់សមាជិក និងលេខាធិការគណៈកម្មការពិសេសរួមមាន លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី, ឯកឧត្តមបណ្ឌិត ថៃម វីឡា៉, ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី, ឯកឧត្តមបណ្ឌិត នាង ផាត, ឯកឧត្តម អ៊ុំ សារីទ្ធ, ឯកឧត្តម ងី ច័ន្ទ្រផល, ឯកឧត្តម ឡាយ សំកុល, ឯកឧត្តមបណ្ឌិត ភឹម រុនស៊ីណារិទ្ធិ, ឯកឧត្តម ប៊ុន វុទ្ធា, លោកជំទាវ សួន ពុធថាវី, លោកជំទាវ សុខ លក្ខិណា, លោក រស់ សុភារុធ និង លោក ឃិន យូរ៉ាន់ ដែលបានរួមចំណែកយ៉ាងសកម្មក្នុងដំណើរការសិក្សាស្រាវជ្រាវនេះ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះ គណៈកម្មការពិនិត្យអត្ថបទសិក្សានៃសាកលវិទ្យាល័យជាតិគ្រប់គ្រងរួមមាន ឯកឧត្តមសាស្ត្រាចារ្យ ហោ ប៉េង, សាស្ត្រាចារ្យរង គង់ ផល្លៈ, សាស្ត្រាចារ្យរង ណុប កញ្ញារិទ្ធិ, សាស្ត្រាចារ្យជំនួយ គឹម វារ៉ា, និងសាស្ត្រាចារ្យជំនួយ ប៉ុក ភារុន ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្ដល់ជាតុចូលផ្នែកបច្ចេកទេស ដើម្បីឱ្យអត្ថបទនេះកាន់តែសុក្រឹត។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះ ឯកឧត្តមបណ្ឌិត សន ពៅ ដែលបានជួយពិនិត្យឃ្លាល្បះ និងអក្ខរាវិរុទ្ធលើអត្ថបទស្រាវជ្រាវនេះ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា តំណាងគណបក្សនយោបាយសម្ព័ន្ធភាព តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងក្រសួងមហាផ្ទៃ តំណាងក្រសួងយុត្តិធម៌ តំណាងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង

ស្រុក ខណ្ឌ ឃុំ សង្កាត់ និងតំណាងក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា ដែលបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ និងបានផ្តល់ធាតុចូលសម្រាប់ការសិក្សាស្រាវជ្រាវនេះ។

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនាឆ្នាំ២០២៦



**បណ្ឌិត ធន់ វឌ្ឍនា**

# មាតិកា


សេចក្តីថ្លែងអំណរគុណ ....................i
សង្ខេបខ្លី ....................១
១. សេចក្តីផ្តើម ....................២
២. វិធីសាស្ត្រស្រាវជ្រាវ ....................៤
៣. លទ្ធផល ....................៦
៣.១. កម្រិតដែនដីរដ្ឋបាល ....................៦
៣.២. ប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ប្រទេសមួយចំនួន ..៩
៣.២.១. សភាជាន់ខ្ពស់កម្ពុជា ....................៩
៣.២.២. សភាជាន់ខ្ពស់ជប៉ុន ....................១០
៣.២.៣. សភាជាន់ខ្ពស់ម៉ាឡេស៊ី ....................១១
៣.២.៤. សភាជាន់ខ្ពស់ហ្វីលីពីន ....................១២
៣.២.៥. សភាជាន់ខ្ពស់ថៃ ....................១៣
៣.២.៦. សភាជាន់ខ្ពស់ឥណ្ឌូណេស៊ី ....................១៥
៣.៣. ការវិភាគប្រៀបធៀប ....................១៧
៣.៣.១. ភាពតំណាង និងគណនេយ្យភាព ....................១៧
៣.៣.២. ប្រសិទ្ធភាពគណនេយ្យភាព ....................២១
៤. សន្និដ្ឋាន ....................២៣
៥. អនុសាសន៍ ....................២៤
ឯកសារយោង ....................២៦

# សិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតព្រឹទ្ធសភា កម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី[1]

## សង្ខេបខ្លី


អត្ថបទនេះ វិភាគប្រៀបធៀបប្រព័ន្ធបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់នៅកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី ឆ្ពោះទៅពង្រឹងភាពតំណាង និងគណនេយ្យភាពសភា ដោយផ្តោតលើ វិធីសាស្ត្របោះឆ្នោត មណ្ឌលបោះឆ្នោត ចំនួនអាសនៈ និងអាណត្តិ ដើម្បីស្វែងរកអនុសាសន៍សម្រាប់កម្ពុជា ពង្រឹងមុខងារសភាឱ្យកាន់តែមានប្រសិទ្ធភាព។

លទ្ធផលស្រាវជ្រាវ បង្ហាញថា ប្រព័ន្ធបោះឆ្នោតសភាជាន់ខ្ពស់មានលក្ខណៈផ្សេងៗគ្នាទៅតាមប្រទេសនីមួយៗ។ កម្ពុជា ម៉ាឡេស៊ី និងថៃ មានប្រព័ន្ធបោះឆ្នោតអសកល រីឯប្រទេសជប៉ុន ហ្វីលីពីន និងឥណ្ឌូណេស៊ី មានប្រព័ន្ធបោះឆ្នោតសកល។ មណ្ឌលបោះឆ្នោតហ្វីលីពីន និងថៃ ស្ថិតនៅកម្រិតជាតិ រីឯមណ្ឌលបោះឆ្នោតម៉ាឡេស៊ីនិងឥណ្ឌូណេស៊ី ស្ថិតនៅរដ្ឋបាលដែនដីកម្រិត១ (កម្រិតរដ្ឋ / ខេត្ត)។ ជប៉ុន មានមណ្ឌលបោះឆ្នោតនៅកម្រិតជាតិ និងនៅដែនដីរដ្ឋបាលកម្រិត១ រីឯកម្ពុជា មានមណ្ឌលបោះឆ្នោតតាមភូមិភាគ (រាជធានី / ខេត្តមួយ ឬ បណ្តុំខេត្តច្រើន) គឺស្ថិតនៅចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១។ ចំពោះចំនួនសមាជិកសភាជាន់ខ្ពស់ក្នុងមណ្ឌលបោះឆ្នោតនីមួយៗ ចំនួនគឺស្មើ


[1] អត្ថបទនេះសរសេរដោយក្រុមស្រាវជ្រាវដែលរួមមាន ធន់ វឌ្ឍនា ហោ ប៉េង រស់ សុភារុជ និង គឹម រុនស៊ីណារិទ្ធិ

គ្នាឬមិនស្មើគ្នា ដោយអាស្រ័យទៅតាមប្រទេសនីមួយៗ។ ម៉ាឡេស៊ី មានសមាជិកសភាជាន់ខ្ពស់ចំនួន ២រូប ក្នុង១មណ្ឌលបោះឆ្នោត ឥណ្ឌូណេស៊ី មានចំនួន ៤រូប ក្នុង១មណ្ឌលបោះឆ្នោត រីឯថៃ មាន ១០រូប ក្នុងមួយក្រុមវិជ្ជាជីវៈ ឬក្រុមសង្គម។ ករណី កម្ពុជា និងជប៉ុន ចំនួនសមាជិកសភាជាន់ខ្ពស់អាស្រ័យទៅតាមមណ្ឌលតូចឬធំ។ បន្ថែមពីនេះ អាណត្តិរបស់សមាជិកសភាជាន់ខ្ពស់ កម្ពុជា ជប៉ុន និងហ្វីលីពីន គឺ៦ឆ្នាំ ឥណ្ឌូណេស៊ី និងថៃ គឺ៥ឆ្នាំ និងម៉ាឡេស៊ី គឺ៣ឆ្នាំ។

ជាការសន្និដ្ឋាន កម្ពុជាមានមណ្ឌលបោះឆ្នោត ស្ថិតនៅចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ ពោលគឺខុសពីប្រទេសផ្សេងៗទៀត ប៉ុន្តែកម្ពុជាមានចំនួនសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលនីមួយៗអាស្រ័យទៅតាមមណ្ឌលតូចឬធំ ដែលស្រដៀងទៅនឹងជប៉ុន។ ដើម្បីធានាភាពតំណាង និងគណនេយ្យភាពសភា មណ្ឌលបោះឆ្នោតគួរស្ថិតនៅក្នុងដែនដីរដ្ឋបាលកម្រិត១ កម្រិត២ ឬកម្រិត៣។ ការសិក្សានេះស្នើថា ដើម្បីពង្រឹងភាពតំណាង និងគណនេយ្យភាពព្រឹទ្ធសភាកម្ពុជា មណ្ឌលបោះឆ្នោត គួរកែសម្រួលពីកម្រិតភូមិភាគ ទៅដែនដីរដ្ឋបាលកម្រិត១ដោយចំនួនសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលបោះឆ្នោតនីមួយៗអាស្រ័យតាមទំហំមណ្ឌលបោះឆ្នោត។

## ១. សេចក្តីផ្តើម

ប្រព័ន្ធសភាពីរជាន់សម័យទំនើប ដែលមានសភាជាន់ខ្ពស់ និងសភាជាន់ទាប ចាប់កំណើតដំបូងនៅអង់គ្លេសក្នុងសតវត្សរ៍ទី១៧ នៅពេលដែលប្រទេសមួយចំនួន មានការរៀបចំឱ្យមានប្រព័ន្ធរដ្ឋាភិបាលអាស្រ័យរដ្ឋធម្មនុញ្ញ ហើយប្រព័ន្ធសភានេះបានរីករាលដាលដល់ប្រទេសផ្សេងៗ

ទៀតលើសកលលោក (Augustyn, 2025)។ សម្រាប់ទ្វីបអាស៊ី ប្រព័ន្ធសភាពីរជាន់នេះត្រូវបានរៀបចំបង្កើតឡើងដំបូងគេក្នុងប្រទេសជប៉ុននៅឆ្នាំ១៨៨៩ (Constitution of Japan, 1889)។ សភាជាន់ខ្ពស់ ត្រូវបានបង្កើតឡើងដើម្បីពិនិត្យបន្ថែមលើកិច្ចការរបស់សភាជាន់ទាប ការងារនីតិកម្ម ការតាមដានការអនុវត្តច្បាប់ និងការសម្រេចបញ្ហាជាតិសំខាន់ៗ។

នៅដើមទសវត្សរ៍១៩៧០ ប្រទេសចំនួន ៤៥ ក្នុងពិភពលោកមានសភាពីរជាន់ (France Senate, 2025)។ បច្ចុប្បន្ន ប្រទេសដែលមានសភាពីរជាន់បានកើនឡើងដល់៨១ប្រទេស (IPU, 2025) ខណៈដែលបណ្ដាប្រទេសមួយចំនួនទៀតកំពុងពិចារណា ឬកំពុងដំណើរការបង្កើតសភាពីរជាន់ (France Senate, 2025)។ កម្ពុជា ក៏ជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានសភាពីរជាន់ដែរ។ ភាពខុសគ្នានៃសភាពីរជាន់នេះ បណ្ដាលមកពីកត្តាសេដ្ឋកិច្ច សង្គម នយោបាយ ប្រវត្តិសាស្ត្រ និងវប្បធម៌។

សភាជាន់ខ្ពស់កម្ពុជា ដែលមានឈ្មោះដើមថា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ ត្រូវបានបង្កើតឡើងដំបូងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ដំណាលគ្នានឹងការបង្កើតរដ្ឋសភាផងដែរ ប៉ុន្តែសភាជាន់ខ្ពស់កម្ពុជាត្រូវបានលុបចោលក្នុងឆ្នាំ១៩៧៥ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (PIC, 2017)។ សភាជាន់ខ្ពស់កម្ពុជា ត្រូវបានបង្កើតឡើងវិញនៅឆ្នាំ១៩៩៩ ដែលមានឈ្មោះថា ព្រឹទ្ធសភា។ ការបង្កើតស្ថាប័ននេះ គឺជាព្រឹត្តិការណ៍នយោបាយដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រ ដោយបានបង្ហាញនូវពន្លឺថ្មីមួយសម្រាប់ព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រឹងពង្រីក ស្មារតីបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ ស្ថិរភាពនយោបាយ និងការប្ដេជ្ញាចិត្តក្នុងការ

កសាងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងនីតិរដ្ឋ។ សមាជិកព្រឹទ្ធសភានីតិកាលដំបូង ត្រូវបានតែងតាំងចេញពីក្នុងចំណោមសមាជិក-សមាជិកា នៃគណបក្សនយោបាយចំនួនបី ដែលមានអាសនៈនៅរដ្ឋសភាមានជាអាទិ៍ គណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ី។ ចាប់តាំងពីនីតិកាលទី២ ឆ្នាំ២០០៦ សមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតអសកល ពីអង្គបោះឆ្នោតដែលជាតំណាងរាស្ត្រក្នុងតំណែងនិងជាសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទាំងអស់ក្នុងតំណែង នៅក្នុងក្របខ័ណ្ឌនៃភូមិភាគនីមួយៗ[2]។

អត្ថបទនេះ វិភាគប្រៀបធៀបប្រព័ន្ធបោះឆ្នោតសភាជាន់ខ្ពស់នៅប្រទេសកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី ដោយផ្ដោតលើ របៀបជ្រើសតាំងសមាជិកព្រឹទ្ធសភា មណ្ឌលបោះឆ្នោត និងចំនួនអាសនៈ ក្នុងគោលបំណងផ្ដល់អនុសាសន៍សម្រាប់កម្ពុជា ពង្រឹងភាពតំណាង គណនេយ្យភាពសភា និងប្រសិទ្ធភាពការងាររបស់សមាជិកព្រឹទ្ធសភា។ អត្ថបទស្រាវជ្រាវនេះ ចែកចេញជា៥ផ្នែកសំខាន់ៗរួមមាន ផ្នែកទី១ សេចក្ដីផ្ដើម ផ្នែកទី២ វិធីសាស្ត្រស្រាវជ្រាវ ផ្នែកទី៣ លទ្ធផល ផ្នែកទី៤ សន្និដ្ឋាន និងផ្នែកទី៥ អនុសាសន៍។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយ ក្រុមស្រាវជ្រាវរបស់គណៈកម្មការពិសេសព្រឹទ្ធសភា ដែលមានសមាសភាព១៤រូប និងត្រូវបានបែងចែកជា ៣ក្រុម។ ក្រុមទី១ សិក្សាលើករណីកម្ពុជា ក្រុមទី២

---

[2] មាត្រា ១០ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

សិក្សាលើករណីប្រទេសបារាំង អូស្ត្រាលី អាម៉េរិក កាណាដា និងចក្រភពអង់គ្លេស រីឯក្រុមទី៣ សិក្សាលើករណីប្រទេសជប៉ុន ម៉ាឡេស៊ី ហ្វីលីពីនថៃ និងឥណ្ឌូណេស៊ី។ ការសិក្សាស្រាវជ្រាវនេះ គឺផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ក្រុមទី១ និងក្រុមទី៣។

ក្រុមទី១ និងក្រុមទី៣ បានសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យនិងព័ត៌មានដែលត្រូវបានបោះពុម្ពផ្សាយរួចជាស្រេច ( Secondary Data ) ចេញពីប្រភពផ្សេងៗ រួមមាន រដ្ឋធម្មនុញ្ញ ច្បាប់ ទិនានុប្បវត្តិសិក្សា អត្ថបទស្រាវជ្រាវ សៀវភៅ របាយការណ៍ ឯកសារគោលនយោបាយ ទស្សនាវដ្ដីកាសែត និងគេហទំព័រផ្លូវការមួយចំនួនរបស់ស្ថាប័នពាក់ព័ន្ធ។ បន្ទាប់មកក្រុមស្រាវជ្រាវបានវិភាគ និងសំយោគឯកសារទាំងនេះ សម្រាប់កិច្ចប្រជុំពិភាក្សាចំនួន៧លើក ដើម្បីជានាសុក្រឹតភាព និងសង្គតិភាព នៃអត្ថបទនេះ។

សិក្ខាសាលាប្រឹក្សាយោបល់មួយត្រូវបានរៀបចំកាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៥ ដើម្បីប្រមូលធាតុចូលបន្ថែម ពីតំណាងភាគីពាក់ព័ន្ធ រួមមាន សមាជិកព្រឹទ្ធសភា គណៈកម្មការទាំង១០នៃរដ្ឋសភា គណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និង ក្រុមប្រឹក្សាសាកលវិទ្យាធិការនៃកម្ពុជា។

## ៣. លទ្ធផល

### ៣.១. កម្រិតដែនដីរដ្ឋបាល

ជាទូទៅ ប្រទេសភាគច្រើនបែងចែកដែនដីរដ្ឋបាលជា៣កម្រិត។ ការបែងចែកកម្រិតផ្សេងៗគ្នានេះ គឺអាចបណ្តាលមកពីឥទ្ធិពលនៃកត្តាវប្បធម៌ ប្រវត្តិសាស្ត្របន្តគ្នារបស់ប្រទេសនីមួយៗ សង្គម សេដ្ឋកិច្ច នយោបាយ ឬឥទ្ធិពលនៃអាណាព្យាបាលឬអាណានិគមរបស់ប្រទេសមហាអំណាចធំៗ ដែលបានដាក់មកលើប្រទេសតូចៗ។ អត្ថបទស្រាវជ្រាវនេះ បរិយាយពីដែនដីរដ្ឋបាលត្រឹម៣កម្រិត របស់ប្រទេសកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី ដូចមានបង្ហាញក្នុងតារាង១។

ដែនដីរដ្ឋបាលទាំង៣កម្រិតនៅកម្ពុជាមាន រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។ ដែនដីរដ្ឋបាលទាំង៣កម្រិតនៅជប៉ុនមាន ខេត្ត/តំបន់រដ្ឋបាល (Prefecture) ក្រុង/ស្រុក (City/District) និងក្រុងរង (Municipality)។ ដែនដីរដ្ឋបាលទាំង៣កម្រិតនៅម៉ាឡេស៊ីមាន រដ្ឋ/ដែនដី (State/Territory) ស្រុក (District) និងស្រុករង (Sub-district)។ ដែនដីរដ្ឋបាលទាំង៣កម្រិតនៅហ្វីលីពីនមាន តំបន់ (Region) ខេត្ត (Province) និងក្រុង (City)។ ដែនដីរដ្ឋបាលទាំង៣កម្រិតនៅថៃមាន ខេត្ត (Province) ស្រុក (District) និងស្រុករង (Sub-district/Tambon)។ ដែនដីរដ្ឋបាលទាំង៣កម្រិតនៅឥណ្ឌូណេស៊ីមាន ខេត្ត (Province) ក្រុង (Regency/City) និងស្រុក (District)។

### តារាង ១: ដែនដីរដ្ឋបាល ៣កម្រិត

| ប្រទេស | កម្រិត១ | កម្រិត២ | កម្រិត៣ |
|---|---|---|---|
| កម្ពុជា[3] | រាជធានី/ខេត្ត | ក្រុង/ស្រុក/ខណ្ឌ | ឃុំ/សង្កាត់ |
| ជប៉ុន | ខេត្ត/តំបន់រដ្ឋបាល Prefecture | ក្រុង/ស្រុក City/District | ក្រុងរង Municipality |
| ម៉ាឡេស៊ី | រដ្ឋ/ដែនដី State/Territory | ស្រុក District | ស្រុករង Sub-district |
| ហ្វីលីពីន | តំបន់ Region | ខេត្ត Province | ក្រុង City |
| ថៃ | ខេត្ត Province | ស្រុក District | ស្រុករង Sub-district/ Tambon |
| ឥណ្ឌូណេស៊ី | ខេត្ត Province | ក្រុង Regency/City | ស្រុក District |

**ប្រភព:** https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country

ចំពោះដែនដីរដ្ឋបាល ដែលត្រូវបានប្រើប្រាស់សម្រាប់ជាមណ្ឌលបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់របស់ប្រទេសទាំង៦នេះ ក៏ខុសគ្នាដែរ។ ប្រទេសហ្វីលីពីននិងថៃ មានមណ្ឌលបោះឆ្នោតនៅកម្រិតជាតិ រីឯជប៉ុនមានមណ្ឌលបោះឆ្នោតកម្រិតជាតិផង និងដែនដីរដ្ឋបាល

[3] មាត្រា១៤៥._ថ្មី (មួយ) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

កម្រិត១ផង។ ចំពោះឥណ្ឌូណេស៊ី និងម៉ាឡេស៊ី មានមណ្ឌលបោះឆ្នោតនៅដែនដីរដ្ឋបាលកម្រិត១ ដោយឡែក កម្ពុជាមានមណ្ឌលបោះឆ្នោតកម្រិតភូមិភាគ (រាជធានី / ខេត្តមួយ ឬបណ្តុំខេត្តផ្សេងៗ) ដែលស្ថិតនៅចន្លោះដែនដីកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ (សូមមើលតារាងទី២)។

### តារាង ២: កម្រិតដែនដីរដ្ឋបាលសម្រាប់ ការបោះឆ្នោតសភាជាន់ខ្ពស់

| ល.រ | ប្រទេស | កម្រិតដែនដីរដ្ឋបាល |
|---|---|---|
| ១ | ហ្វីលីពីន ថៃ | ជាតិ |
| ២ | កម្ពុជា | ភូមិភាគ (រាជធានី/ខេត្តមួយ ឬបណ្តុំខេត្ត) |
| ៣ | ជប៉ុន | កម្រិត១ (Prefecture) & ជាតិ |
| ៤ | ឥណ្ឌូណេស៊ី ម៉ាឡេស៊ី | កម្រិត១ (ខេត្ត/State) |

**ប្រភព:** https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country

ខាងលើនេះ បង្ហាញអំពីការបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ ទៅតាមមណ្ឌលបោះឆ្នោតនីមួយៗ ដែលស្ថិតក្នុងកម្រិតជាតិ ឬដែនដីរដ្ឋបាលកម្រិតផ្សេងៗ ទៅតាមប្រទេសនីមួយៗ។ ការបោះឆ្នោតកម្រិតជាតិ សមាជិកសភាជាន់ខ្ពស់មានគណនេយ្យភាព និងការទទួលខុសត្រូវទូលំទូលាយកម្រិតជាតិ រីឯការបោះឆ្នោតនៅដែនដីរដ្ឋបាលកម្រិត១ សមាជិកសភាជាន់ខ្ពស់នៅតែមានគណនេយ្យភាព និងការទទួលខុសត្រូវទូលំទូលាយកម្រិតជាតិ ប៉ុន្តែពួកគាត់ជាទូទៅយកចិត្ត

ទុកដាក់ទៅលើអង្គបោះឆ្នោតមកពីមណ្ឌលបោះឆ្នោតរបស់ខ្លួន ច្រើនជាងអង្គបោះឆ្នោតមកពីមណ្ឌលបោះឆ្នោតផ្សេងទៀត។

## ៣.២. ប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ប្រទេសមួយចំនួន

ផ្នែកនេះ នឹងលើកអំពីប្រព័ន្ធជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ កម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី ដែលផ្តោតទៅលើការពន្យល់អំពី មុខងារ អាណត្តិ អាសនៈ ប្រព័ន្ធបោះឆ្នោត និងមណ្ឌលបោះឆ្នោត។

### ៣.២.១. សភាជាន់ខ្ពស់កម្ពុជា

សភាជាន់ខ្ពស់កម្ពុជា ត្រូវបានបង្កើតឡើងដំបូងក្នុងឆ្នាំ១៩៤៧ បើផ្អែកលើមាត្រា៧៨ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ និងមានឈ្មោះថា ក្រុមប្រឹក្សាព្រះរាជអាណាចក្រ។ សភាជាន់ខ្ពស់កម្ពុជាត្រូវបានលុបបំបាត់ក្នុងឆ្នាំ១៩៧៥ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (PIC, 2017) ប៉ុន្តែ ស្ថាប័ននេះត្រូវបានបង្កើតឡើងវិញក្នុងឆ្នាំ១៩៩៩ ដែលបច្ចុប្បន្នមានឈ្មោះថា ព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate។ ព្រឹទ្ធសភាកម្ពុជា មានមុខងារស្នូលបី គឺមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ព្រមទាំងមានមុខងារគាំទ្រចំនួនពីរទៀត គឺការទូតសភា និងមុខងារអភិវឌ្ឍស្ថាប័ន។ ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ និងសមាជិកសរុបចំនួន ៦២រូប ដែលសមាជិកចំនួន ២រូប ត្រូវបានជ្រើសតាំងតាមមតិភាគច្រើនដោយប្រៀបដោយរដ្ឋសភា សមាជិកចំនួន២រូបទៀត ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និងសមាជិកចំនួន ៥៨រូប ត្រូវបានជ្រើសតាំងតាមការបោះឆ្នោត។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ត្រូវបានធ្វើឡើងជាអសកល ដែលអ្នកបោះឆ្នោត និងអង្គបោះឆ្នោត គឺជាតំណាងរាស្ត្រក្នុងតំណែង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងតំណែងតាមមណ្ឌលភូមិភាគទាំង៨។ ភាគច្រើននៃភូមិភាគទាំងនេះ ជាបណ្តុំនៃដែនដីរដ្ឋបាលកម្រិត១។ ការយកភូមិភាគធ្វើជាមណ្ឌលបោះឆ្នោតរបស់ព្រឹទ្ធសភា គឺខុសពីរដ្ឋសភាដែលយកដែនដីរដ្ឋបាលកម្រិត១ជាមណ្ឌលបោះឆ្នោត ហើយក៏ខុសពីការអនុវត្តក្នុងបណ្តាប្រទេសផ្សេងៗដែរ។ ការបែងចែកអាសនៈទៅតាមភូមិភាគ គឺអាស្រ័យទៅលើទំហំ ឬចំនួនអង្គបោះឆ្នោតក្នុងភូមិភាគនីមួយៗ ហើយការបែងចែកអាសនៈត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត (D'Hondt Method) ដោយមិនគិតសំណល់ចែក (គ.ជ.ប ឆ្នាំ២០២៣)។

### ៣.២.២. សភាជាន់ខ្ពស់ជប៉ុន

សភាជាន់ខ្ពស់ជប៉ុន ត្រូវបានបង្កើតក្នុងឆ្នាំ១៩៤៧ ស្របតាមរដ្ឋធម្មនុញ្ញ ដែលរៀបចំក្រោយពីចប់សង្គ្រាមលោកលើកទី២ និងមានឈ្មោះថា សភាប្រឹក្សា ជាភាសាអង់គ្លេសហៅថា House of Councillors និងរៀបចំជ្រើសតាំងសមាជិកព្រឹទ្ធសភារបស់ខ្លួនដោយការបោះឆ្នោតសកលស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ (Kobori, 2020)។ សភាប្រឹក្សាជប៉ុន មានមុខងារ ផ្តួចផ្តើមគំនិតធ្វើច្បាប់ វិសោធនកម្មច្បាប់ និងអនុម័តច្បាប់ (Reed, 2003)។ សភាប្រឹក្សាក៏ដើរតួយ៉ាងសំខាន់ក្នុងការតំណាងផលប្រយោជន៍ផ្សេងៗក្នុងប្រទេស ដោយធានាថាទាំងដែនដីរដ្ឋបាលនីមួយៗ និងការគ្រប់គ្រងថ្នាក់ជាតិទាំងមូល ត្រូវបានយកចិត្តទុកដាក់ក្នុងដំណើរការនីតិប្បញ្ញត្តិ ដើម្បីធានាតុល្យភាពអំណាច ក្នុង

ក្របខ័ណ្ឌនយោបាយជប៉ុនទាំងមូល។ សភាប្រឹក្សាមានអាណត្តិ៦ឆ្នាំ និងសមាជិកសរុបចំនួន ២៤៨រូប ដែលសមាជិកចំនួន ១៤៨រូប ត្រូវបានបោះឆ្នោតតាមប្រព័ន្ធឯកត្តនាម ដើម្បីតំណាងនៅដែនដីរដ្ឋបាលកម្រិត១ (៤៥ Prefectures) និងចំនួន១០០រូបទៀតត្រូវបានបោះឆ្នោតតាមរយៈគណបក្សនយោបាយ ដើម្បីតំណាងឱ្យកម្រិតជាតិ (Scheiner, 2012)។

ពាក់កណ្ដាលនៃសមាជិកសភាប្រឹក្សា ត្រូវបានបោះឆ្នោតរៀងរាល់៣ឆ្នាំម្ដង[4] (Kobori, 2020)។ ការរៀបចំការបោះឆ្នោតរៀងរាល់ ៣ឆ្នាំម្ដងនេះ បានជួយឱ្យការរៀបចំ និងការប្រព្រឹត្តទៅរបស់សភាប្រឹក្សាជប៉ុន មានដំណើរការដោយរលូន និងមានស្ថិរភាព បើទោះបីជាការរៀបចំបែបនេះ តម្រូវឱ្យមានការចំណាយលើការរៀបចំការបោះឆ្នោតច្រើនជាងការរៀបចំការបោះឆ្នោតរៀងរាល់ ៦ឆ្នាំម្ដងក៏ដោយ។

### ៣.២.៣. សភាជាន់ខ្ពស់ម៉ាឡេស៊ី

សភាជាន់ខ្ពស់ម៉ាឡេស៊ី ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៧ និងមានឈ្មោះថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ឬភាសាម៉ាឡេស៊ីហៅថា Dewan Negara។ រដ្ឋធម្មនុញ្ញម៉ាឡេស៊ីឆ្នាំ១៩៥៧ បានចែងពីការជ្រើសតាំងសមាជិកព្រឹទ្ធសភា តាមការបោះឆ្នោតអសកល និងតាមការតែងតាំងរបស់ព្រះមហាក្សត្រ ដើម្បីតំណាងឱ្យផលប្រយោជន៍របស់រដ្ឋនីមួយៗ និងសហព័ន្ធទាំងមូល (Harding & Chin, 2021;

[4] ចំនួនសមាជិកសភាប្រឹក្សាពាក់កណ្ដាលបានបំពេញការងារ៣ឆ្នាំ មុនសមាជិកចំនួនពាក់កណ្ដាលផ្សេងទៀត ដែលជាទូទៅសមាជិកសភាប្រឹក្សាចំនួនពាក់កណ្ដាលនឹងផុតអាណត្តិមុនសមាជិកពាក់កណ្ដាលទៀត ដោយតម្រូវឱ្យមានការបោះឆ្នោតរៀងរាល់ ៣ឆ្នាំម្ដង ដើម្បីបំពេញមកវិញនូវសមាជិកដែលផុតអាណត្តិទាំងនោះ។

Malaysia's Constitution 1957)។ ព្រឹទ្ធសភា ម៉ាឡេស៊ី មានមុខងារ ផ្តួចផ្តើមគំនិតធ្វើច្បាប់ ធ្វើវិសោធនកម្មច្បាប់ និងពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ដែលអនុម័តដោយ Dewan Rakyat។ ព្រឹទ្ធសភាក៏មានតួនាទីយ៉ាងសំខាន់ ដើម្បីតំណាងឱ្យផលប្រយោជន៍រដ្ឋនីមួយៗនិងរដ្ឋសហព័ន្ធ ដោយធានាថាផលប្រយោជន៍ទាំងនោះត្រូវបានយកចិត្តទុកដាក់ក្នុងដំណើរការនីតិប្បញ្ញត្តិ ដើម្បីធានាតុល្យភាពអំណាចក្នុងក្របខ័ណ្ឌនយោបាយម៉ាឡេស៊ីទាំងមូល។ ព្រឹទ្ធសភាមានអាណត្តិ៣ឆ្នាំ និងសមាជិកសរុបចំនួន ៧០រូប (Parliament of Malaysia, 2021)។

ក្នុងចំណោមសមាជិកព្រឹទ្ធសភាទាំងអស់ សមាជិកចំនួន ២៦រូប ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតអសកលនៅដែនដីរដ្ឋបាលកម្រិត១ ដោយសភាក្នុងរដ្ឋរបស់ខ្លួន (State Legislative Assemblies) ដើម្បីតំណាងឱ្យរដ្ឋនីមួយៗ (សមាជិកព្រឹទ្ធសភាចំនួន២រូបក្នុង១រដ្ឋ ទោះបីរដ្ឋនោះតូចឬធំក៏ដោយ)។ សមាជិកព្រឹទ្ធសភាចំនួន ៤៤រូបទៀត ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ (Yang di-Pertuan Agong) តាមការស្នើសុំរបស់នាយករដ្ឋមន្ត្រី (Harding & Chin, 2021) ដើម្បីតំណាងឱ្យដែនដីទាំង៣ និងប្រទេសជាតិទាំងមូល។

### ៣.២.៤. **សភាជាន់ខ្ពស់ហ្វីលីពីន**

សភាជាន់ខ្ពស់ហ្វីលីពីន ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៦ និងមានឈ្មោះថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ដែលសមាជិកព្រឹទ្ធសភាត្រូវបានជ្រើសតាំងតាមការបោះឆ្នោតសកល (Senate of the Philippines, 2025)។ ព្រឹទ្ធសភាហ្វីលីពីន មានមុខងារ ផ្តួចផ្តើមគំនិតធ្វើច្បាប់ ធ្វើវិសោធនកម្មច្បាប់ ត្រួតពិនិត្យការអនុវត្តច្បាប់ អនុម័តច្បាប់

យល់ព្រមលើសន្ធិសញ្ញា និងសម្រេចដកតំណែងប្រធានាធិបតី (Library of Congress, n.d.)។ ព្រឹទ្ធសភាក៏មានតួនាទីយ៉ាងសំខាន់ ដើម្បីតំណាងឱ្យផលប្រយោជន៍ជាតិទាំងមូល ដោយធានាថាផលប្រយោជន៍ទាំងនោះត្រូវបានយកចិត្តទុកដាក់ ក្នុងដំណើរការនីតិកម្ម ដើម្បីធានាតុល្យភាពអំណាចក្នុងក្របខ័ណ្ឌនយោបាយហ្វីលីពីនទាំងមូល។ ព្រឹទ្ធសភាមានអាណត្តិ៦ឆ្នាំ និងសមាជិកសរុបចំនួន ២៤រូប ។

ពាក់កណ្ដាលនៃសមាជិកព្រឹទ្ធសភា ត្រូវបានបោះឆ្នោតរៀងរាល់៣ឆ្នាំម្តង[5] (Libarios & Ramirez, 2025; Teehankee, 2020)។ ការរៀបចំការបោះឆ្នោតរៀងរាល់ ៣ឆ្នាំម្ដងនេះ បានជួយឱ្យការរៀបចំ និងការប្រព្រឹត្តទៅរបស់ព្រឹទ្ធសភាហ្វីលីពីន មានដំណើរការដោយរលូន និងមានស្ថិរភាព បើទោះបីជាការរៀបចំបែបនេះ តម្រូវឱ្យមានការចំណាយលើការរៀបចំការបោះឆ្នោត ច្រើនជាងការរៀបចំការបោះឆ្នោតរៀងរាល់ ៦ឆ្នាំម្តងក៏ដោយ។ ការបោះឆ្នោតត្រូវបានរៀបចំឡើងតាមប្រព័ន្ធឯកត្តនាម ហើយសមាជិកព្រឹទ្ធសភាហ្វីលីពីន តំណាងឱ្យប្រទេសទាំងមូល និងមិនមានការបែងចែកអាសនៈតាមខេត្តនោះទេ។

### ៣.២.៥. សភាជាន់ខ្ពស់ថៃ

សភាជាន់ខ្ពស់ថៃ មានឈ្មោះថាព្រឹទ្ធសភា ជាភាសាអង់គ្លេសហៅថា Senate ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៤៦ និងបានធ្វើកំណែទម្រង់បន្តបន្ទាប់រហូតដល់ឆ្នាំ២០២៤។ ព្រឹទ្ធសភាថៃ បានផ្លាស់ប្តូរពី

[5] ចំនួនសមាជិកសភាប្រឹក្សាពាក់កណ្ដាលបានបំពេញការងារ៣ឆ្នាំ មុនសមាជិកចំនួនពាក់កណ្ដាលផ្សេងទៀត ដែលជាទូទៅសមាជិកសភាប្រឹក្សាចំនួនពាក់កណ្ដាលនឹងផុតអាណត្តិមុនសមាជិកពាក់កណ្ដាលទៀត ដោយតម្រូវឱ្យមានការបោះឆ្នោតរៀងរាល់ ៣ឆ្នាំម្តង ដើម្បីបំពេញមកវិញនូវសមាជិកដែលផុតអាណត្តិទាំងនោះ។

ស្ថាប័នដែលសមាជិកព្រឹទ្ធសភាកើតចេញពីការតែងតាំង ទៅជាស្ថាប័នព្រឹទ្ធសភាដែលសមាជិកត្រូវបានជ្រើសតាំងតាមការបោះឆ្នោតអសកលក្នុងចំណោមបេក្ខជនដែលបានចុះឈ្មោះក្នុងបញ្ជីបេក្ខភាពសមាជិកព្រឹទ្ធសភា (Colignon, 2024; Senate of Thailand, n.d.; UK House of Commons Library, 2024)។ ព្រឹទ្ធសភាថៃ មានមុខងារ ផ្តួចផ្តើមគំនិតធ្វើច្បាប់ ធ្វើវិសោធនកម្មច្បាប់ តាមដានការអនុវត្តច្បាប់ ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ និងតែងតាំងសមាជិកគណៈកម្មការបោះឆ្នោតនិងតុលាការធម្មនុញ្ញ ប៉ុន្តែព្រឹទ្ធសភាគ្មានសិទ្ធិបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីនោះទេ។ ព្រឹទ្ធសភាដើរតួយ៉ាងសំខាន់សម្រាប់ផលប្រយោជន៍ផ្សេងៗ ជាពិសេសក្រុមវិជ្ជាជីវៈ និងក្រុមសង្គមផ្សេងៗដែលខ្លួនតំណាង។ ព្រឹទ្ធសភាមានមានអាណត្តិ៥ឆ្នាំនិងសមាជិកសរុបចំនួន ២០០រូប ប៉ុន្តែសមាជិកទាំងនេះមិនអាចឈរឈ្មោះជាបេក្ខជនសមាជិកព្រឹទ្ធសភាជាថ្មីឡើងវិញបានទេ នៅអាណត្តិបន្ទាប់គ្នានោះ។

សមាជិកព្រឹទ្ធសភាទាំង ២០០រូប ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតអសកលពីក្រុមវិជ្ជាជីវៈ និងក្រុមសង្គមផ្សេងៗ សរុបចំនួន ២០ ក្រុម (១០រូប / ក្រុម)។ អង្គបោះឆ្នោត ដែលត្រូវជ្រើសតាំងសមាជិកព្រឹទ្ធសភា ជាបេក្ខជនដែលបានចុះឈ្មោះ ក្នុងបញ្ជីឈរឈ្មោះបេក្ខភាពសមាជិកព្រឹទ្ធសភា (Collignon, 2024)។ តាមរយៈការបោះឆ្នោតអសកលនេះ បេក្ខជនឈរឈ្មោះត្រូវប្រកួតប្រជែងក្នុងក្រុមវិជ្ជាជីវៈ និងក្រុមសង្គមផ្សេងៗគ្នា ចាប់ពីថ្នាក់ស្រុក ថ្នាក់ខេត្ត រហូតដល់ថ្នាក់ជាតិ។

### ៣.២.៦. សភាជាន់ខ្ពស់ឥណ្ឌូណេស៊ី

សភាជាន់ខ្ពស់ឥណ្ឌូណេស៊ី មានឈ្មោះថាក្រុមប្រឹក្សាតំណាងតំបន់ ជាភាសាអង់គ្លេសហៅថា Regional Representative Council ឬភាសាឥណ្ឌូណេស៊ីហៅថា Dewan Perwakilan Daerah ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ១៩៥០ ប៉ុន្តែត្រូវបានលុបបំបាត់វិញនៅខែសីហា ឆ្នាំ១៩៥០។ នៅឆ្នាំ២០០៤ ក្រុមប្រឹក្សាតំណាងតំបន់ ត្រូវបានបង្កើតជាផ្លូវការឡើងវិញ ដែលសមាជិកក្រុមប្រឹក្សាតំណាងតំបន់ ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតសកល និងតំណាងឱ្យដែនដីរដ្ឋបាលកម្រិត១ (IFES, 2024; Wikipedia, n.d)។ ក្រុមប្រឹក្សាតំណាងតំបន់ មានមុខងារផ្តួចផ្តើមគំនិតធ្វើច្បាប់ តាមដានការអនុវត្តច្បាប់ ពិនិត្យហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ (Sherlock, 2007)។ ក្រុមប្រឹក្សាតំណាងតំបន់ ក៏ដើរតួយ៉ាងសំខាន់ក្នុងការតំណាងផលប្រយោជន៍ជាតិ ដោយយកចិត្តទុកដាក់ក្នុងដំណើរការនីតិប្បញ្ញត្តិ ដើម្បីធានាតុល្យភាពអំណាចក្នុងក្របខ័ណ្ឌនយោបាយឥណ្ឌូណេស៊ីទាំងមូល។ ក្រុមប្រឹក្សាតំណាងតំបន់មានអាណត្តិ៥ឆ្នាំ និងសមាជិកសរុបចំនួន ១៥២រូប ដែលត្រូវតែជាបុគ្គលឯករាជ្យ និងមិនមែនជាសមាជិកគណបក្សនយោបាយណាមួយនោះទេ (EPRS, 2024)។

អាសនៈនៅក្នុងខេត្តនីមួយៗ មានចំនួនស្មើគ្នា មិនអាស្រ័យលើចំនួនប្រជាជននៅក្នុងខេត្តនោះទេ។ សមាជិកក្រុមប្រឹក្សាតំណាងតំបន់ត្រូវបានជ្រើសតាំងតាមការបោះឆ្នោតសកលនៅដែនដីរដ្ឋបាលកម្រិត១ និងមានចំនួន ៤រូបក្នុង១ខេត្ត (IFES, 2024 ;Tukan, J & ALW, L.

2018; Suparto, 2019)។ សមាជិកទាំងនោះអាចឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាតំណាងតំបន់ជាថ្មីឡើងវិញ នៅអាណត្តិបន្ទាប់គ្នា។

តារាង ខាងក្រោមប្រៀបធៀបចំនួនអាសនៈ អាណត្តិ ចំនួនសមាជិកសភាជាន់ខ្ពស់ កម្រិតមណ្ឌលបោះឆ្នោត និងចំនួនមណ្ឌលបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់របស់ប្រទេសកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពី ថៃ និងឥណ្ឌូណេស៊ី។

## តារាង ៣: តារាងប្រៀបធៀបប្រព័ន្ធព្រឹទ្ធសភា / សភាជាន់ខ្ពស់ នៃបណ្តាប្រទេសនៅអាស៊ី

| បរិយាយ | កម្ពុជា | ជប៉ុន | ម៉ាឡេស៊ី | ហ្វីលីពីន | ថៃ | ឥណ្ឌូណេស៊ី |
|---|---|---|---|---|---|---|
| អាសនៈ | ៦២ | ២៤៨ | ៧០ | ២៤ | ២០០ | ១៥២ |
| អាណត្តិ (ឆ្នាំ) | ៦ | ៦ | ៣ | ៦ | ៥ | ៥ |
| សមាជិកសភាជាន់ខ្ពស់ | -បោះឆ្នោតអសកល ៥៨ -ចាត់តាំង /ជ្រើសតាំង ៤ | បោះឆ្នោតសកល | -បោះឆ្នោតអសកល ២៦ -ចាត់តាំង /ជ្រើសតាំង ៤៤ | បោះឆ្នោតសកល | បោះឆ្នោតអសកល | បោះឆ្នោតសកល |
| មណ្ឌលបោះឆ្នោត | កម្រិតភូមិភាគ + តែងតាំង | ដែនដីកម្រិត១ + កម្រិតជាតិ | ដែនដីកម្រិត១ + តែងតាំង | កម្រិតជាតិ | កម្រិតជាតិ | ដែនដីកម្រិត១ |

| | | | | | | |
|---|---|---|---|---|---|---|
| ចំនួនមណ្ឌលបោះឆ្នោត | ៨ភូមិភាគ | ៤៥ខេត្ត + ជាតិ | ១៣រដ្ឋ + ៣ដែនដី | ១ | ១ | ៣៨ខេត្ត |

**ប្រភព:** Inter-Parliamentary Union (IPU) https://data.ipu.org/ , Constitute Project https://www.constituteproject.org/ , and Wikipedia https://en.wikipedia.org/wiki/D%27Hondt_method#cite_note-25

## ៣.៣. ការវិភាគប្រៀបធៀប

ការសិក្សាប្រៀបធៀបប្រព័ន្ធបោះឆ្នោតសមាជិកសភាជាន់ខ្ពស់ប្រទេសកម្ពុជា ជប៉ុន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងឥណ្ឌូណេស៊ី បានបង្ហាញពីការប្រើប្រាស់វិធីសាស្ត្រផ្សេងគ្នា ក្នុងការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ ដែលមានឥទ្ធិពលដល់មុខងារតំណាង និងគណនេយ្យភាព។

### ៣.៣.១. ភាពតំណាង និងគណនេយ្យភាព

ភាពតំណាងរបស់សមាជិកសភាជាន់ខ្ពស់ សំដៅលើដំណើរការដែលសមាជិកសភាជាន់ខ្ពស់ សម្តែងមតិ និងធ្វើសកម្មភាពផ្សេងៗ ដើម្បីការពារផលប្រយោជន៍ប្រជាជន ជាពិសេសអ្នកបោះឆ្នោត ឬអង្គបោះឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរបស់ខ្លួន ឬអ្នកដែលបានតែងតាំងខ្លួន។ រីឯគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ សំដៅលើការទទួលខុសត្រូវ ឬការឆ្លើយតបរបស់សមាជិកសភាជាន់ខ្ពស់ម្នាក់ៗ ចំពោះសាធារណជន ជាពិសេសអ្នកបោះឆ្នោតឬអង្គបោះឆ្នោត លើបញ្ហាច្បាប់ សកម្មភាព និងការសម្រេចចិត្តនានារបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ភាពតំណាង ឬគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ មានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ សមាជិកសភាជាន់ខ្ពស់តំណាងឱ្យប្រជាជនទូទាំងប្រទេស ប៉ុន្តែពួកគាត់តែងតែយកចិត្តទុកដាក់

ជាចម្បងចំពោះអ្នកបោះឆ្នោត / អង្គបោះឆ្នោត ក្នុងមណ្ឌលរបស់គាត់ ឬ អ្នកជ្រើសតាំង / តែងតាំងគាត់។ ជាទូទៅ សមាជិកសភាជាន់ខ្ពស់ ត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតសកលឬអសកល ក្រៅពីនេះក៏មានសមាជិកព្រឹទ្ធសភាមួយចំនួនកើតចេញពីការជ្រើសតាំង ឬ តែងតាំង ផងដែរ។

សមាជិកសភាជាន់ខ្ពស់នៅជប៉ុន ហ្វីលីពីន និងឥណ្ឌូណេស៊ី កើតចេញពីការបោះឆ្នោតសកល ប៉ុន្តែភាពតំណាងរបស់ពួកគាត់ខុសៗគ្នា។ នៅជប៉ុន សមាជិកសភាជាន់ខ្ពស់ភាគច្រើនកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋក្នុងដែនដីរដ្ឋបាលកម្រិត១ ក្នុងពេលដែលសមាជិកមួយចំនួនទៀតកើតចេញពីការបោះឆ្នោតកម្រិតជាតិ។ សមាជិកសភាជាន់ខ្ពស់ទាំងអស់នៅឥណ្ឌូណេស៊ី កើតចេញពីការបោះឆ្នោតនៅដែនដីរដ្ឋបាលកម្រិត១ រីឯនៅហ្វីលីពីនកើតចេញពីការបោះឆ្នោតនៅកម្រិតជាតិ។ ភាពតំណាងរបស់សភាជាន់ខ្ពស់ ជាទូទៅគឺតំណាងឱ្យអ្នកបោះឆ្នោតទូទាំងប្រទេស ប៉ុន្តែសមាជិកសភាជាន់ខ្ពស់ដែលកើតចេញពីការបោះឆ្នោតតាមមណ្ឌល តែងតែយកចិត្តទុកដាក់ជាពិសេសលើបញ្ហាតែក្នុងមណ្ឌលរបស់ខ្លួន។

សមាជិកសភាជាន់ខ្ពស់នៅកម្ពុជា ម៉ាឡេស៊ី និងថៃ កើតចេញពីការបោះឆ្នោតអសកល ប៉ុន្តែភាពតំណាងរបស់ពួកគាត់ខុសៗគ្នា។ យោងតាមច្បាប់ សមាជិកសភាជាន់ខ្ពស់កម្ពុជា តំណាងឱ្យប្រជាជាតិខ្មែរទាំងមូល ប៉ុន្តែពួកគាត់យកចិត្តទុកដាក់ជាចម្បងលើបញ្ហាទាំងឡាយណាដែលឡើងចំពោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអ្នកបោះឆ្នោត។ លើសពីនេះទៅទៀត សមាជិកសភាជាន់ខ្ពស់ទាំងនោះយកចិត្តទុកដាក់ជា

ពិសេសក្នុងមណ្ឌលភូមិភាគរបស់ខ្លួន។ ភាពតំណាងរបស់សមាជិកសភាជាន់ខ្ពស់ គឺអាស្រ័យលើចំនួនអង្គបោះឆ្នោត នៅក្នុងមណ្ឌលបោះឆ្នោតរៀងៗខ្លួន។ ភាពតំណាងរបស់សមាជិកសភាជាន់ខ្ពស់ម៉ាឡេស៊ី គឺតំណាងឱ្យកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ ដែលជាមណ្ឌលបោះឆ្នោត។ ចំណែកឯសមាជិកសភាជាន់ខ្ពស់ថៃ កើតចេញពីការបោះឆ្នោតអសកលដោយក្រុមវិជ្ជាជីវៈ ឬក្រុមសង្គមផ្សេងៗ។ ហេតុដូច្នេះ ភាពតំណាងរបស់គាត់មិនផ្ដោតលើដែនដីរដ្ឋបាលកម្រិតណាមួយជាក់លាក់នោះទេ ប៉ុន្តែផ្ដោតលើក្រុមវិជ្ជាជីវៈ ឬក្រុមសង្គម។

សភាជាន់ខ្ពស់ ដែលអនុវត្តប្រព័ន្ធបោះឆ្នោតសកលដូចជានៅជប៉ុន ហ្វីលីពីន និងឥណ្ឌូណេស៊ី ទទួលខុសត្រូវដោយផ្ទាល់ចំពោះអ្នកបោះឆ្នោត ហើយធានានូវភាពស្របច្បាប់តាមលទ្ធិប្រជាធិបតេយ្យ (Kobori, 2020; Teehankee, 2020; IFES, 2024 and Tukan, J & ALW, L. 2018)។ រីឯសភាជាន់ខ្ពស់ដែលអនុវត្តប្រព័ន្ធបោះឆ្នោតអសកល ដូចជានៅកម្ពុជា និងម៉ាឡេស៊ី មានទំនួលខុសត្រូវចំពោះមន្ត្រីមូលដ្ឋាន ហើយធ្វើឱ្យមានតុល្យភាពឥទ្ធិពលពីមូលដ្ឋានជាមួយនឹងគោលនយោបាយជាតិ (Collignon, 2024; UK House of Commons Library, 2024; Harding & Chin, 2021)។ ដោយឡែកថៃ មានទំនួលខុសត្រូវជាចម្បងចំពោះក្រុមវិជ្ជាជីវៈ ឬក្រុមសង្គមផ្សេងៗ។ ប្រព័ន្ធបោះឆ្នោត មានឥទ្ធិពលលើគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ ជាមួយអ្នកបោះឆ្នោត ជាពិសេសអ្នកដែលបោះឆ្នោតផ្ទាល់។ ក្រៅពីនេះ ការទទួលខុសត្រូវនិងគណនេយ្យភាពសភា ក៏អាស្រ័យទៅតាមចំនួនអាសនៈ និងវិសាលភាពនៃមណ្ឌលបោះឆ្នោតនីមួយៗ។ ការមានអាសនៈច្រើនក្នុង

មណ្ឌលបោះឆ្នោតមានវិសាលភាពធំ អាចមានប្រសិទ្ធភាពទាបជាងការមានអាសនៈតិចក្នុងមណ្ឌលបោះឆ្នោតមានវិសាលភាពតូច ព្រោះការធ្វើដំណើរ ការប្រមូលផ្តុំ ការចាត់ចែងកិច្ចការតូចធំនានា ត្រូវធ្វើជាក្រុម ហើយមានការលំបាក និងប្រសិទ្ធភាពទាប។ រីឯអាសនៈតិចក្នុងមណ្ឌលបោះឆ្នោតមានវិសាលភាពតូច អាចធ្វើឱ្យសមាជិកសភាជាន់ខ្ពស់ ជួបអង្គបោះឆ្នោតរបស់ខ្លួនបានញឹកញាប់ មានភាពសកម្ម និងមានការទទួលខុសត្រូវខ្ពស់។

ការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់តាមរយៈការបោះឆ្នោតសកល ដូចមាននៅជប៉ុន ហ្វីលីពីន និងឥណ្ឌូណេស៊ី ធានានូវគណនេយ្យភាពសមាជិកសភាជាន់ខ្ពស់ចំពោះអ្នកបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន ដែលជាទូទៅមានចំនួនអ្នកបោះឆ្នោតច្រើន។ ថៃ មានការបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ជាអសកល ដោយក្រុមវិជ្ជាជីវៈ ឬក្រុមសង្គមផ្សេងៗ ដូច្នេះគណនេយ្យភាពរបស់សមាជិកសភាជាន់ខ្ពស់ ឆ្លើយតបទៅនឹងក្រុមវិជ្ជាជីវៈ ឬក្រុមសង្គម ជាជាងឆ្លើយតបទៅនឹងប្រជាជនក្នុងតំបន់ណាមួយ។ រីឯការជ្រើសតាំងសមាជិកសភាជាន់ខ្ពស់តាមរយៈការបោះឆ្នោតអសកល ដូចមាននៅកម្ពុជា និងម៉ាឡេស៊ី ដែលជាទូទៅមានចំនួនអ្នកបោះឆ្នោតតិចជាងការបោះឆ្នោតសកល ធ្វើឱ្យគណនេយ្យភាពសភាមានជាពិសេសជាមួយអង្គបោះឆ្នោត នៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន។ មណ្ឌលបោះឆ្នោតរបស់ម៉ាឡេស៊ី គឺជាដែនដីរដ្ឋបាលកម្រិត១ ដោយឡែកមណ្ឌលបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់នៅកម្ពុជា គឺជាមណ្ឌលភូមិភាគ ដែលជាបណ្តុំនៃខេត្ត ពោលគឺនៅចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាល

កម្រិត១។ ការយកមណ្ឌលភូមិភាគជាមណ្ឌលបោះឆ្នោតដូចនៅកម្ពុជា មិនមែនជាការអនុវត្តទូទៅនៅបណ្តាប្រទេសផ្សេងៗទេ ព្រោះថា មណ្ឌលបោះឆ្នោតជាទូទៅ គឺស្ថិតនៅកម្រិតជាតិ ឬដែនដីរដ្ឋបាលកម្រិត១។

### ៣.៣.២. ប្រសិទ្ធភាពគណនេយ្យភាព

ប្រសិទ្ធភាពគណនេយ្យភាពសភា សំដៅទៅលើ ឬពាក់ព័ន្ធទៅនឹងការធ្វើយ៉ាងណាឱ្យការអនុវត្តច្បាប់ ឬគោលនយោបាយនានា ឱ្យទទួលបានលទ្ធផលល្អ ទាន់ពេលវេលា និងដោយចំណាយសមរម្យ។ គណនេយ្យភាពសភា មានទំនាក់ទំនងជាមួយប្រព័ន្ធ ឬរបៀបនៃការបោះឆ្នោតជ្រើសតាំងសមាជិកសភាជាន់ខ្ពស់ ព្រោះវាជាចំណងដ៏សំខាន់រវាងអ្នកឈរឈ្មោះបោះឆ្នោតនិងអ្នកបោះឆ្នោត ពោលគឺធ្វើឱ្យអ្នកជាប់ឆ្នោតមានទំនួលខុសត្រូវលើការសន្យារបស់ខ្លួន ក្នុងអំឡុងពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត។

ការបោះឆ្នោតសកល បង្កើនធម្មានុរូបប្រជាធិបតេយ្យ ផ្តល់អំណាចដល់និងលើកកម្ពស់ការចូលរួមពីពលរដ្ឋ ដែលជាទូទៅត្រូវបានចាត់ទុកថាជាការអនុវត្តតាមគោលការណ៍ប្រជាធិបតេយ្យពេញលេញ។ ក្នុងដំណើរការប្រជាធិបតេយ្យ អ្នកជាប់ឆ្នោតជាអ្នកមានប្រជាប្រិយភាព ហើយអ្នកមានប្រជាប្រិយភាពមិនប្រកដថាសុទ្ធតែជាអ្នកមានសមត្ថភាពនោះទេ។ លើសពីនេះទៀត ការរៀបចំការបោះឆ្នោតនឹងត្រូវចំណាយពេលវេលា ធនធានមនុស្ស និងថវិកាច្រើន ដែលមានលក្ខណៈខុសគ្នាពីការបោះឆ្នោតអសកល។

ជាទូទៅ នីតិកាលសភាជាន់ខ្ពស់ អាចមានរយៈពេលចន្លោះពី៣ឆ្នាំ ទៅ៦ឆ្នាំ អាស្រ័យទៅតាមប្រទេសនីមួយៗ ហើយភាពញឹកញាប់នៃ

ការបោះឆ្នោតក៏អាស្រ័យទៅតាមប្រទេសនីមួយៗផងដែរ។ នីតិកាលរបស់សភាជាន់ខ្ពស់កម្ពុជានិងឥណ្ឌូណេស៊ីមានរយៈពេល៦ឆ្នាំ ថៃមានរយៈពេល៥ឆ្នាំ ម៉ាឡេស៊ីមានរយៈពេល៣ឆ្នាំ និងបោះឆ្នោតធ្វើឡើងតែម្តងក្នុងមួយនីតិកាលសម្រាប់ជ្រើសតាំងមាជិកទាំងអស់។ រីឯ ជប៉ុននិងហ្វីលីពីន នីតិកាលរបស់សភាជាន់ខ្ពស់ មានរយៈពេល៦ឆ្នាំ ហើយការបោះឆ្នោតធ្វើឡើងរៀងរាល់៣ឆ្នាំម្តង ដើម្បីជ្រើសតាំងសមាជិក៥០% នៃសមាជិកទាំងអស់។ ការបោះឆ្នោតម្តងសម្រាប់ជ្រើសតាំងសមាជិកតែពាក់កណ្តាល នៃសមាជិកទាំងអស់ អាចធានាបានអភិបាលកិច្ចប្រកបដោយនិរន្តរភាព ស្ថិរភាពនៃស្ថាប័ន និងសង្គតិភាពកិច្ចការ ប៉ុន្តែត្រូវចំណាយខ្ពស់ជាងការបោះឆ្នោតតែម្តងសម្រាប់ជ្រើសតាំងសមាជិកទាំងអស់។

នីតិកាលសភាជាន់ខ្ពស់ដែលមានរយៈពេលវែង ធ្វើឱ្យស្ថាប័នមានស្ថិរភាព និងអនុញ្ញាតឱ្យសមាជិកសភាអភិវឌ្ឍជំនាញ និងផ្តោតលើការធ្វើផែនការគោលនយោបាយរយៈពេលវែង។ ប៉ុន្តែរយៈពេលវែងនេះធ្វើឱ្យសមាជិកសភាជាន់ខ្ពស់ពុំសូវរងសម្ពាធក្នុងការរក្សានិងស្វែងរកការគាំទ្រពីអ្នកបោះឆ្នោត ដែលអាចធ្វើឱ្យមានគម្លាតរវាងពួកគាត់។ ផ្ទុយទៅវិញ នីតិកាលរយៈពេលខ្លី ធ្វើឱ្យសមាជិកសភាជាន់ខ្ពស់ចាំបាច់ទទួលខុសត្រូវ និងឆ្លើយតបទៅនឹងតម្រូវការភ្លាមៗរបស់អ្នកបោះឆ្នោត។ យ៉ាងណាក៏ដោយ នីតិកាលខ្លីពេក នឹងធ្វើឱ្យស្ថាប័នសភាជាន់ខ្ពស់ទោរទន់ទៅរកតែសំឡេងឆ្នោតនិងប្រជាប្រិយភាពនៅនីតិកាលបន្ទាប់ ដោយផ្តោតការធ្វើច្បាប់ឬគោលនយោបាយរយៈពេលខ្លី ជាជាងផលប្រយោជន៍រយៈពេលវែង។

ចំពោះមណ្ឌលបោះឆ្នោតដែលមានវិសាលភាពដែនដីធំទូលាយ ជាទូទៅធ្វើឱ្យការជួបប្រាស្រ័យទាក់ទងផ្ទាល់រវាងសមាជិកសភាជាន់ខ្ពស់ជាមួយអ្នកបោះឆ្នោត គឺមិនបានញឹកញាប់ និងមិនស្និទ្ធស្នាល។ ជាមួយគ្នានេះដែរ ការស្វែងរកដំណោះស្រាយជូនប្រជាជន អំពីកង្វល់និងសំណូមពរ ឱ្យបានទាន់ពេលវេលានិងចំគោលដៅ អាចនៅមានកម្រិត ហើយការចំណាយទាំងធនធានមនុស្ស ពេលវេលា ព្រមទាំងថវិកា គឺច្រើនជាងមណ្ឌលបោះឆ្នោតដែលមានវិសាលភាពដែនដីតូច។ ជាទូទៅ មណ្ឌលបោះឆ្នោតតូច អនុញ្ញាតឱ្យសមាជិកសភាជាន់ខ្ពស់ជួបអ្នកបោះឆ្នោតរបស់ខ្លួនញឹកញាប់ និងមានទំនាក់ទំនងជិតស្និទ្ធ ហេតុដូច្នេះ ការដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានា អាចធ្វើឡើងទាន់ពេលវេលាចំគោលដៅ និងចំណាយសមរម្យ ដើម្បីទទួលបានលទ្ធផលល្អគាប់ចិត្ត។

### ៤. សន្និដ្ឋាន

មណ្ឌលបោះឆ្នោតហ្វីលីពីននិងថៃ ស្ថិតនៅកម្រិតជាតិ រីឯមណ្ឌលបោះឆ្នោតម៉ាឡេស៊ីនិងឥណ្ឌូណេស៊ី ស្ថិតនៅដែនដីរដ្ឋបាលកម្រិត១ (កម្រិតរដ្ឋ / ខេត្ត)។ ជប៉ុន មានមណ្ឌលបោះឆ្នោតនៅកម្រិតជាតិ និងនៅដែនដីរដ្ឋបាលកម្រិត១។ ដោយឡែក មណ្ឌលបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាកម្ពុជាត្រូវបានរៀបចំនៅតាមមណ្ឌលកម្រិតភូមិភាគ (រាជធានី / ខេត្តមួយ ឬ បណ្តុំខេត្តច្រើន) ដែលស្ថិតនៅចន្លោះកម្រិតជាតិ និងដែនដីរដ្ឋបាលកម្រិត១ គឺមានភាពខុសប្លែកពីប្រទេសខាងលើ។ ជាការសន្និដ្ឋាន ទោះបីកម្ពុជាមានមណ្ឌលបោះឆ្នោតខុសប្លែកពីប្រទេសផ្សេងៗទៀតក៏ដោយ កម្ពុជាមានចំនួនសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលនីមួយៗ អាស្រ័យទៅតាមមណ្ឌលតូច-ធំ ដែលស្រដៀងទៅនឹង

ជប៉ុន។ ដើម្បីធានាភាពតំណាង និងគណនេយ្យភាពសភា មណ្ឌលបោះឆ្នោតគួរស្ថិតនៅក្នុងដែនដីរដ្ឋបាលកម្រិត១ កម្រិត២ ឬកម្រិត៣។ ការសិក្សានេះស្នើថា ដើម្បីពង្រឹងភាពតំណាង និងគណនេយ្យភាពព្រឹទ្ធសភាកម្ពុជា មណ្ឌលបោះឆ្នោត គួរកែសម្រួលពីកម្រិតភូមិភាគ ទៅដែនដីរដ្ឋបាលកម្រិត១ ដោយចំនួនសមាជិកព្រឹទ្ធសភាក្នុងមណ្ឌលបោះឆ្នោតនីមួយៗ អាស្រ័យតាមទំហំមណ្ឌលបោះឆ្នោត។

## ៥. អនុសាសន៍

- គប្បីពិចារណាបែងចែកអាសនៈតាមខេត្ត៖ ព្រឹទ្ធសភាកម្ពុជាគប្បីប្ដូរពីការបែងចែកអាសនៈតាមភូមិភាគទាំង ៨ ទៅកម្រិតរាជធានី-ខេត្តទាំង២៥ វិញ (ដូចការអនុវត្ត នៅរដ្ឋសភា) ដើម្បីបង្កើនគណនេយ្យភាពចំពោះអង្គបោះឆ្នោត ធានាទំនាក់ទំនងកាន់តែជិតស្និទ្ធរវាងសមាជិកព្រឹទ្ធសភា និងសហគមន៍មូលដ្ឋាន។
- គប្បីពិចារណាបែងចែកចំនួនអាសនៈទៅតាមទំហំមណ្ឌលបោះឆ្នោត៖ ចំនួនសមាជិកព្រឹទ្ធសភាតាមមណ្ឌលនីមួយៗ គួរបន្តរក្សាទៅតាមទំហំមណ្ឌលតូច ឬធំ ហើយហោចណាស់មានសមាជិកម្នាក់ក្នុង១ខេត្ត / មណ្ឌល។
- នាពេលអនាគត គួរសិក្សាស្រាវជ្រាវបន្ថែមលើការរៀបចំមណ្ឌលបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅដែនដីរដ្ឋបាលកម្រិត២ (ស្រុក) ដោយរក្សាអាសនៈយ៉ាងច្រើនស្មើពាក់កណ្ដាលនៃអាសនៈសរុបរដ្ឋសភា៖ ភាពជាតំណាងឱ្យដែនដីតូច និងមានចំនួនអង្គបោះឆ្នោតសមស្រប ជួយឱ្យសមាជិកព្រឹទ្ធសភា បង្កើនទំនាក់

ទំនងជាមួយអង្គបោះឆ្នោតកាន់តែជិតស្និទ្ធ ងាយស្រួលបង្ហាញស្នាដៃក្នុងការអភិវឌ្ឍមូលដ្ឋាន និងលើសពីនេះ អាចសិក្សាគោលនយោបាយដែលជាលក្ខណៈពិសេសរបស់មូលដ្ឋាន ដើម្បីដាក់ជូនរាជរដ្ឋាភិបាល។

# ឯកសារយោង


1. List of administrative divisions by country
   https://en.m.wikipedia.org/wiki/List_of_administrative_divisions_by_country
2. France Senate
   https://www.senat.fr/europe-et-international/senats-deurope-senats-du-monde/forum-of-the-worlds-senates.html
3. Inter-Parliamentary Union
   https://www.ipu.org/national-parliaments
4. Augustyn. A., (2025). bicameral system. Britannica.
   https://www.britannica.com/topic/bicameral-system

## ប្រទេសកម្ពុជា

1. រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧
   https://silaka.org/wp-content/files_mf/1423472677Constitution_of_Cambodia_1947_Khm.pdf
2. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣
   https://www.mcs.gov.kh/update-2023
3. សារវតារព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា (២០២៥)
   https://senate.gov.kh/about-senate/senate-history/
4. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (២០១៧)
   https://senate.gov.kh/wp-content/plugins/senatedoc/uploads/Law%20on%20the%20Election%20of%20Members%20of%20the%20National%20Assembly%20and%20Senators%202023.pdf

5. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប): បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា (២០២៣)
https://www.nec.gov.kh/khmer/sites/default/files/download-files/regulations_and_procedures_2024.pdf
6. Parliamentary Institute of Cambodia. (2017): The Nature and Functions of Cambodia Parliament and Government https://pcasia.org/pic/wp-content/uploads/simple-file-list/20171227_The-Nature-and-Functions-of-Cambodias-Parliament-and-Government_Kh.pdf

## ប្រទេសថៃ

1. Collignon, S. (2024). *Electing the Thai Senate: A passage to democracy?* https://www.stefancollignon.de/wp-content/uploads/2024/12/Senate_Thailand_11.pdf
2. UK House of Commons Library. (2024). *Thailand: Political developments 2023–24 and the banning of the Move Forward Party* (Briefing Paper No. CBP-10141). https://researchbriefings.files.parliament.uk/documents/CBP-10141/CBP-10141.pdf
3. Senate of Thailand. (n.d.). *The Senate under the transitory provisions of the Constitution of the Kingdom of Thailand.* https://www.senate.go.th/assets/portals/1/fileups/419/files/senate%20Eng.pdf

## ប្រទេសម៉ាឡេស៊ី

1. Parliament of Malaysia. (2021). *Standing Orders of the Senate (Dewan Negara).* https://www.parlimen.gov.my/images/webuser/files/PMDN-ENG.pdf

2. Harding, A., & Chin, J. (2021). Reforming the Dewan Negara: Its evolution and options for reform. *Journal of Malaysian Parliament*, 1, 1–20. https://journalmp.parlimen.gov.my/jurnal/index.php/jmp/article/download/55/26
3. Malaysia's Constitution of 1957 with Amendments through 1996 https://faolex.fao.org/docs/pdf/mal132821.pdf

## ប្រទេសហ្វីលីពីន

1. Libarios, R., & Ramirez, A. (2025). Examining how candidate attributes shape Gen Z perceptions for the 2025 Philippine Senate elections using conjoint analysis. *Asian Journal of Politics and Governance.* https://www.researchgate.net/publication/387204541
2. Teehankee, J. (2020). How voters combine candidates on the ballot: The case of the Philippine senatorial elections. *Philippine Political Science Journal, 41*(2), 112–130. https://www.researchgate.net/publication/288834466
3. Library of Congress. (n.d.). *Senatorial candidates' matrices – Philippine election.* https://www.loc.gov/resource/gdcovop.2012330724/
4. Senate of the Philippines. (2025). History of the Senate. https://legacy.senate.gov.ph/about/history.asp#:~:text=Although%20the%20Philippine%20Legislature%20was,the%20Constitution%20of%20the%20Philippines.

## ប្រទេសជប៉ុន

1. Constitution of Japan. (1889). https://www.constituteproject.org/constitution/Japan_1889
2. Scheiner, E. (2012). The electoral system and Japan's partial transformation. *Japanese Electoral Studies*, 1(1), 1–20. https://scheiner.faculty.ucdavis.edu/wp-

content/uploads/sites/755/2022/08/scheiner_2012_jeas.pdf

3. Kobori, M. (2020). Singular belief about separate bicameral elections in Japan. *Ritsumeikan Law Review, 40*, 55–70. https://www.ritsumei.ac.jp/acd/cg/law/lex/rlr40/004KOBORI%20Masahiro.pdf
4. Reed, S. R. (2003). *Japanese electoral politics: Creating a new party system*. Nordic Institute of Asian Studies. https://library.oapen.org/bitstream/id/94b0e555-c099-44eb-8b83-7594296584d9/1005920.pdf

## ប្រទេសឥណ្ឌូណេស៊ី

1. IFES (2024). Elections in Indonesia 2024 General Elections Frequently Asked Questions. https://www.ifes.org/sites/default/files/2024-02/2024_Elections_FAQ_Final.pdf
2. EPRS (2024). Political institutions in Indonesia after the October 2024 elections Democracy, decentralisation, diversity https://www.europarl.europa.eu/RegData/etudes/BRIE/2020/646149/EPRS_BRI(2020)646149_EN.pdf
3. Sherlock (2007). Parliamentary Indicators of Indonesia: House of Representatives (DPR) and House of Regional Representatives (DPD) https://documents1.worldbank.org/curated/en/249401468188934594/pdf/81128-ParliamentaryIndicatorsIndonesia-Box-377336B-PUBLIC.pdf
4. Tukan, J & ALW, L. (2018). DPD (Regional Representative Council), As a State Agency of Indonesian State System, Runs The Authority of Its Role and Function to Create the Existence of Bicameral System in Indonesia

https://ejournal.undip.ac.id/index.php/dlr/article/view/19271/13805

5. Suparto (2019). The Existence of Indonesian Regional Representatives Council as The State Institution on Carrier the Regional Aspirations. 3rd International Conference on Globalization of Law and Local Wisdom (ICGLOW 2019). Advances in Social Science, Education and Humanities Research, volume 358 file:///C:/Users/Administrator/Downloads/125920839.pdf
6. Regional Representative Council of the Republic of Indonesia https://id.wikipedia.org/wiki/Dewan_Perwakilan_Daerah_Republik_Indonesia




## CONTACT

**ASEAN Economic Research Institute (AERI)**

National University of Management,
International Campus, Khan Chbar
Ampov, Phnom Penh

www.aeri.num.edu.kh

aeri@num.edu.kh